ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៥១៥..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលចំនួនគណៈអភិបាលខេត្ត

04.05.11

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានកែសម្រួលចំនួនគណៈអភិបាលខេត្ត ដោយបន្ថែមអភិបាលរងខេត្តមួយនាក់ សម្រាប់ខេត្តចំនួន **១៧** ដែលមានគណៈអភិបាលខេត្ត ០៥នាក់ និង ០៦នាក់ ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | ខេត្ត បន្ទាយមានជ័យ | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ២- | ខេត្ត កំពង់ស្ពឺ | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៣- | ខេត្ត កំពង់ធំ | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៤- | ខេត្ត កំពង់ឆ្នាំង | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៥- | ខេត្ត កំពត | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៦- | ខេត្ត ស្វាយរៀង | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៧- | ខេត្តពោធិ៍សាត់ | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៨- | ខេត្ត ក្រចេះ | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ៩- | ខេត្ត ព្រះសីហនុ | ពីចំនួន ០៦នាក់ | ទៅជា ០៧នាក់ |
| ១០- | ខេត្ត ព្រះវិហារ | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១១- | ខេត្ត រតនគិរី | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១២- | ខេត្ត កោះកុង | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១៣- | ខេត្ត ស្ទឹងត្រែង | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១៤- | ខេត្ត ឧត្តរមានជ័យ | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១៥- | ខេត្ត មណ្ឌលគិរី | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១៦- | ខេត្ត កែប | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ |
| ១៧- | ខេត្ត ប៉ៃលិន | ពីចំនួន ០៥នាក់ | ទៅជា ០៦នាក់ ។ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*

*ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*ដូចមាត្រា ៣*
*ឯកសារ កាលប្បវត្តិ*